ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ៤៥ ប្រក.សស

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី

## ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/២១ ចុះថ្ងៃ២៩ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- លោកជំទាវ **មាសសាឯម ដានី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- លោកជំទាវ **រស់ ច័ន្ទស្រស់** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- ឯកឧត្តម **ចន វណ្ណៈ** | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម **ថោង សុគន្ធ** | អគ្គនាយកនៃអគ្គនាយដ្ឋានកិច្ចការសង្គម | សមាជិក |

| | | | |
|---|---|---|---|
| ៥- លោក | **សេខ ស៊ីន** | អគ្គនាយករងនៃអគ្គនាយដ្ឋានកិច្ចការសង្គម | សមាជិក |
| ៦- លោក | **គឹម ស្រ៊ុន** | អគ្គនាយករងនៃអគ្គនាយដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៧- លោក | **ជា ផល្លី** | ប្រធាននាយកដ្ឋានសុខាភិបាល សង្គមកិច្ចនិងកិច្ចការនារី | សមាជិកអចិន្ត្រៃយ៍ |
| ៨- លោក | **សំ ម៉ុនណា** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៩- លោកស្រី | **ហាក់ ប៉ោលាន** | ប្រធាននាយកដ្ឋានពិធីការ | សមាជិកា |
| ១០-លោក | **រាត់ សុខជា** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងធនាគារ | សមាជិក |
| ១១-លោកស្រី | **សុវណ្ណា សុវណ្ណារ៉ាវី** | ប្រធាននាយកដ្ឋានរាជកិច្ច | សមាជិកា |
| ១២-លោកស្រី | **ម៉េង ណារី** | អនុប្រធាននាយកដ្ឋានឥស្សរិយយស | សមាជិកា |
| ១៣-លោក | **ស៊ូម៉ៃ សុខគា** | អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញវត្ថុ | សមាជិក |
| ១៤-លោក | **ថង់ ហាក់លាន** | អនុប្រធាននាយកដ្ឋានព័ត៌មាន ប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១៥-លោក | **ជុន រតនា** | អនុប្រធាននាយកដ្ឋានមុខងារសាធារណៈ និងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច | សមាជិក |
| ១៦-លោក | **នូ មុណាឥត្ថិ** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ | សមាជិក។ |

**ប្រការ ២.-**

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រប្រចាំឆ្នាំ សម្រាប់អនុវត្តគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍
- សម្របសម្រួល ណែនាំ និងបង្កលក្ខណៈអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមអង្គភាពនានាចំណុះទីស្តីការគណៈរដ្ឋមន្ត្រីឱ្យមាននិរន្តរភាព
- រៀបចំកម្មវិធី កិច្ចប្រជុំផ្សេងៗដើម្បីផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹងផ្នែកបង្ការ និងទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ដល់មន្ត្រីក្នុងអង្គភាព
- រៀបចំគម្រោងផែនការចំណាយថវិកាជាតិប្រចាំឆ្នាំ ដើម្បីគាំទ្រដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រប្រយុទ្ធនឹងជំងឺអេដស៍ក្នុងអង្គភាព
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រប្រយុទ្ធនឹងជំងឺអេដស៍ តាមកាលកំណត់របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ចូលរួមសហការរាល់សកម្មភាពទប់ស្កាត់ និងកាត់បន្ថយជំងឺអេដស៍ ជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដែលធ្វើការងារនៅក្នុងតំបន់ និងក្នុងរូបភាពជាពហុវិស័យ។

**ប្រការ ៣.-**

ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាននៃរាល់កិច្ចប្រជុំ។ ប្រសិនបើប្រធានអវត្តមាន ប្រធានត្រូវផ្ទេរសិទ្ធិជូនអនុប្រធាន។

**ប្រការ ៤**.-

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី មានសិទ្ធិប្រើត្រាទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបំពេញការងារ។

**ប្រការ ៥**.-

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី មាននាយកដ្ឋានសុខាភិបាល សង្គមកិច្ច និងកិច្ចការនារី នៃអគ្គនាយកដ្ឋានកិច្ចការសង្គម ជាលេខាធិការដ្ឋានជួយដល់ដំណើរការតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ ៦**.-

ការចំណាយសម្រាប់ដំណើរការរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិបដិភាគដែលបានមកពីប្រភពផ្សេងៗទៀត សម្រាប់ដំណើរការងាររបស់ខ្លួន។

**ប្រការ ៧**.-

ប្រកាសលេខ០៥ ប្រក.អវ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំសមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៃទីស្តីការគណៈរដ្ឋមន្ត្រី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨**.-

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសង្គម ប្រធាននាយកដ្ឋានសុខាភិបាល សង្គមកិច្ច និងកិច្ចការនារី គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធានអង្គភាព និងនាយកដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៤កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកក្កដា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**កន្លែងទទួល៖**

- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងសុខាភិបាល
- -ក្រសួងមុខងារសាធារណៈ
- -អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតឧបនាយករដ្ឋមន្ត្រីប្រចាំការ
- -ដូចប្រការ ៨
- -ឯកសារ កាលប្បវត្តិ